រាជបណ្ឌិត្យសភាកម្ពុជា

# «វិមានរំឭកដល់អ្នកស្លាប់ក្នុងសង្គ្រាមលោកលើកទី១»

## ភាគទី៧ វគ្គទី៧


អត្ថបទចងក្រងដោយ៖ លោកស្រី **ស៊ិន ច័ន្ទអមរា**

មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា




ប្រភព : http://www.khmer440.com

ផ្អែកតាមបណ្ណសារស្ដីអំពី«បុន្យឆ្លងវិមានដែរសាងក្នុងក្រុងភ្នំពេញ, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ( ពីឆ្នាំ១៩១៤ដល់ឆ្នាំ១៩១៨)»[1] យើងសូមលើកយកនូវសុន្ទរកថារបស់ដុកទ័រវ៉ាលឡេត៍ (Docteur Vallet) ជាចាងហ្វាងក្រុមសមាគមពួកពិជ័យសង្គ្រាមចាស់[2] យកមកបង្ហាញបន្តដោយលើកយកនូវខ្លឹមសារដើម និងមានការកែសម្រួលមួយចំនួនដូចខាងក្រោម៖

ការណ៍ដែលធ្វើឱ្យចុំប្លើងរុងរឿងដល់ទាហានដែលស្លាប់នេះគឺជាកិច្ចមួយដ៏ប្រសើរដែលយើងត្រូវធ្វើជាចាំបាច់។ ការប្រាប់ឱ្យដឹងអំពីមូលហេតុដែលនាំឱ្យបុគ្គលទាំងនេះស៊ូប្ដូរជីវិតស្លាប់យ៉ាងដូច្នេះនេះ គឺជាកិច្ចមួយដ៏ប្រសើររបស់យើង ដោយហេតុថា បុគ្គលដែលស្លាប់នោះបានទូន្មានយើងដូច្នេះថា«ចូរអ្នកស្រឡាញ់ស្រុករបស់អ្នក ពីព្រោះអ្នករាល់គ្នាកើតឡើងសម្រាប់តែឱ្យស្រឡាញ់ស្រុករបស់ខ្លួន»។ ការស្រឡាញ់ស្រុករបស់ខ្លួននោះអាចរាប់បញ្ចូលទាំង៖ ការស្រឡាញ់គ្រួសារ, ការស្រឡាញ់ស្រែចម្ការ, ការស្រឡាញ់ផ្ទះ, ការស្រឡាញ់ភូមិ និងការស្រឡាញ់សាលាដែលបង្ហាត់បង្រៀនឱ្យចេះអក្សរជាដើម។ ហេតុដូច្នេះហើយបានជាបារាំងសែសនិងខ្មែរ ចេញទៅច្បាំងគ្មានបានត្រឡប់វិលមកវិញ ហើយបានវាចាដូច្នេះថា«ទាំងនេះហើយដែលអ្នកត្រូវស្រឡាញ់នោះ ឯពួកយើងដែលស្លាប់ទៅហើយ យើងពុំអាចស្រឡាញ់បានទៀតឡើយ។ ប៉ុន្តែអ្នកទាំងអស់គ្នាដែលនៅរស់នៅឡើយនេះ ចូរអ្នកចេះតែស្រឡាញ់ស្រុកតទៅមុខកុំខានឡើយ»។ ពាក្យសម្ដីងាយៗទាំងនេះ បានរំឭកនូវពាក្យទូន្មានស្ដីពីសេចក្ដីពិតរបស់អ្នកស្លាប់។ នគរនីមួយៗបានរស់គង់កេរក៏ដោយសារសេចក្ដីពិតនេះឯង។

សូមប្រសិទ្ធិពរជូនដល់អ្នកបាត់បង់ជីវិតទាំងប៉ុន្មាន ដែលស៊ូប្រថុយជីវិតស្លាប់ដោយសារចង់ឱ្យនគរបារាំងសែសបានគង់វង្សល្អតទៅ។

ខ្ញុំបានឮសម្ដីអ្នកដែលស្លាប់នោះនិយាយប្រាប់ខ្ញុំដូច្នេះថា«យើងដែលច្បាំងនេះគឺច្បាំងដោយជួយស្រុកបារាំងសែស និងអាណាប្រជាជនក្នុងជម្ពូទ្វីបឱ្យរួចរស់ ប៉ុន្តែយើងស្អប់ចម្បាំងនេះណាស់ មិនចង់ឱ្យមានចម្បាំងនេះតទៅទៀតទេ»។

ពួកអស់យើងដែលមានជីវិតរស់រួចពីចម្បាំងហើយ និងមានស្មារតីចាំអំពីចម្បាំងនេះនៅឡើយនោះ យើងបានឃើញជាតិសាសន៍២ពួកដែលប្រកួតប្រកាន់ ធ្វើឱ្យអន្តរាយគ្នាទៅវិញទៅមក គឺ១ពួកមាន

---

[1] បុន្យឆ្លងវិមានដែរសាងក្នុងក្រុងភ្នំពេញ, ជាទីរំឭកដល់អស់អ្នក ដែលទទួលអនិច្ចកម្ម ក្នុងចំបាំងធំ(ពីឆ្នាំ១៩១៤ ដល់ឆ្នាំ១៩១៨), នៅក្នុងរាជកិច្ចរាជការ ឆ្នាំ១៩២៥ ទំព័រ១០១-១០៥។

[2] គឺប្រធានសមាគមពួកពិជ័យសង្គ្រាមចាស់ (Président de l’Association des Anciens Tirailleurs)។

គំនិតអាក្រក់ចង់បំផ្លាញដូចកាលពីមុនៗ ១ពួកទៀតមានសេចក្ដីយុត្តិធម៌កាន់ផ្លូវច្បាប់[3]។ យើងត្រូវយល់ccច្បាស់អំពីបញ្ហាទាំងនេះ និងយកសម្ដីរបស់បុគ្គលដែលស្លាប់ទៅហើយនោះ សម្លឹងមើលទៅមុខ សម្លឹងមើលទៅក្រោយ លុះត្រាតែដល់ពេលណាដែលរាស្ដ្រទាំងអស់យល់ឃើញថាជាតិសាសន៍នីមួយៗដែលពូកែនោះ គឺដោយសារតែមានសេចក្ដីសុខក្សេមក្សាន្តក្នុងព្រះនគរ។

យើងទាំងអស់គ្នាពុំចង់ឱ្យកូនចៅយើងរងទុក្ខវេទនាតទៅទៀតទេ។ យើងពុំចង់ឱ្យឪពុកម្ដាយ ស្ត្រីមេម៉ាយ និងកូនកំព្រា កាន់ទុក្ខយំសោកពីសេចក្ដីមោហោទោសោ ដែលបោះបង់ចោលផ្លូវសុចរិត ចេញអស់នោះទេ ត្រូវតែជាតិសាសន៍ទាំងអស់ប្រជុំគ្នាធ្វើឱ្យស្រុះស្រួល មូលមាត់គ្នាទាំងអស់ ត្រូវតែរាស្ដ្រគិតតែពីសេចក្ដីសុខក្សេមក្សាន្ត ទុកគ្នាដូចជាបងប្អូនបង្កើត។

ដូច្នេះយើងត្រូវធ្វើយ៉ាងណាកុំឱ្យមានចម្បាំងនេះតទៅទៀត ហើយមនុស្សដែលកើតជំនាន់ក្រោយៗត្រូវគិតថា យើងកើតមកនេះពុំមែនសម្រាប់តែស្លាប់ដើម្បីស្រុកដូចករណីខាងលើនេះទេ ប៉ុន្តែគឺដើម្បីរស់នៅសម្រាប់ស្រុករបស់ខ្លួនទៅវិញ។

បើធ្វើយ៉ាងដូច្នេះសេចក្ដីបណ្ដាំរបស់ខ្មោចដ៏ប្រសើរនេះ នឹងបានសម្រេចដូចប្រាថ្នា។ ខ្ញុំមានចិត្តសង្ឃឹមជាប្រាកដថាសម្ដីនេះគឺត្រូវដូចពាក្យខ្មោចពិតមែន បើប្រសិនជាខ្មោចទាំងនេះងើបពីក្នុងផ្នូរឡើងបាន ហើយស្រែកថាសេចក្ដីដែលស៊ូប្រថុយជីវិតនេះ គឺពុំឥតប្រយោជន៍ទេ ប៉ុន្តែត្រូវឱ្យអាណាប្រជាជនក្នុងជម្ពូទ្វីបលែងច្បាំងគ្នាទាំងអស់ ដើម្បីឱ្យមនុស្សជំនាន់ក្រោយៗ រកស៊ីធ្វើការជាសុខក្សេមក្សាន្តពេញបរិបូរណ៍ និងបានចម្រើននគរបារាំងសែស ដែលជានគរតែមួយក្នុងទ្វីបលោកនេះ មានពន្លឺរស្មីល្អ ព្រមទាំងសេចក្ដីឯកចិត្តនោះផង។

---

[3] ជាតិសាសន៍ពួកទី១ គឺសំដៅលើប្រទេសអាល្លឺម៉ង់និងសម្ព័ន្ធមិត្តដែលបានរួមកម្លាំងគ្នាប្រឆាំងនឹងជាតិសាសន៍១ពួកទៀតគឺបារាំងនិងអង់គ្លេស តាំងពីចុងសតវត្សរ៍ទី១៩មកម្ល៉េះ។ ដោយមានសម្ពាធពីអាល្លឺម៉ង់ បារាំងនិងអង់គ្លេសបានស្ថាបនាទំនាក់ទំនងការទូតមានឈ្មោះថា«ការស្រុះស្រួលគ្នាជាមិត្តភាព»(Entente cordiale) ចាប់ពីឆ្នាំ១៩០៤ ដែលបានផ្ដល់ឱកាសអំណោយផលសម្រាប់ឱ្យប្រទេសកម្ពុជាយកបានពីប្រទេសសៀមមកវិញជាបន្តបន្ទាប់នូវ៖ ខេត្តម្លូព្រៃ និងទន្លេរពៅ(ព្រះវិហារ) នៅឆ្នាំ១៩០៤ ព្រមទាំងខេត្តសៀមរាប បាត់ដំបង និងសិរីសោភ័ណ នៅឆ្នាំ១៩០៧។ [**Entente Cordiale**, (April 8, 1904), Anglo-French agreement that, by settling a number of controversial matters, ended antagonisms between Great Britain and France and paved the way for their diplomatic cooperation against German pressures in the decade preceding World War I (1914–18)].

ចាងហ្វាងក្រុមសមាគមពួកពិជ័យសង្គ្រាមចាស់ បញ្ចប់សេចក្ដីអធិប្បាយដែលមានតៗមក និងសេចក្ដីអធិប្បាយដែលទើបនឹងមើលអម្បាញ់មិញ ហើយដែលបណ្ដាជនទះដៃសរសើរតែរៀងខ្លួន បុណ្យដែលមានប្រូក្រាម(កម្មវិធី)បញ្ញត្តឱ្យធ្វើនិងចាប់ធ្វើពីពេលនោះមក។

(សូមរង់ចាំអានភាគបន្ត...)